LONGBEACH DEVELOPMENT SERVICES

# PUBLIC NOTICE

# សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ និងភាពមានឯកសារ

នៅថ្ងៃពុធទី 22 ខែមិថុនាឆ្នាំ 2022 វេលាម៉ោង 4:00 រសៀល ក្រុមហ៊ុនវិនិយោគសហគមន៍ទីក្រុងឡុងប៊ិច (CIC) នឹងបើកសវនាការសាធារណៈនៅបន្ទប់សន្និសីទជាន់ទី 2 នៅក្នុងសាលាក្រុងដែលមានអាសយដ្ឋាន 411 West Ocean Boulevard, Long Beach។

គោលបំណងនៃសវនាការសាធារណៈនេះ គឺដើម្បីអនុញ្ញាតឲ្យមានការចូលរួមមតិពីសាធារណជនក្នុងការបង្កើតផែនការរួម (Consolidated Plan) ឆ្នាំ 2022-2027 ក៏ដូចជាផែនការសកម្មភាពឆ្នាំ 2022-2023 វិសោធនកម្មឆ្នាំ 2021 2020 2018 និង 2017 ដែលផ្អែកលើអាទិភាពដែលបានគូសបញ្ជាក់នៅក្នុងផែនការរួម។ ផែនការរួម ពណ៌នាអំពី និងផ្តោតអាទិភាពលើតម្រូវការលំនៅដ្ឋាន និងការអភិវឌ្ឍសហគមន៍ ក៏ដូចជាសកម្មភាពដើម្បីដោះស្រាយតម្រូវការទាំងនោះដូចបានកំណត់ និងឧបត្ថម្ភដោយនាយកដ្ឋានលំនៅដ្ឋាន និងអភិវឌ្ឍន៍ក្រុងសហរដ្ឋអាមេរិក (HUD)។ ដូចបានតម្រូវដោយ HUD ផែនការរួមនាំមកជាមួយគ្នានូវការដាក់ស្នើរួមគ្នាមួយ ការធ្វើផែនការ និងផ្អែកអនុវត្តរបស់ជំនួយប្លុកអភិវឌ្ឍន៍សហគមន៍ (CDBG) ជំនួយដំណោះស្រាយសង្គ្រោះបន្ទាន់ (ESG) និងមូលនិធិកម្មវិធីភាពជាដៃគូវិនិយោគ HOME (HOME) ដើម្បីដោះស្រាយអាទិភាពទាំងនេះ។

សេចក្តីព្រាងនៃផែនការរួម នឹងមានសម្រាប់ការពិនិត្យឡើងវិញជាសាធារណៈរយៈពេល 30 ថ្ងៃ ដែលចាប់ផ្តើមពីថ្ងៃទី 20 ខែឧសភា ឆ្នាំ 2022 ដល់ថ្ងៃទី 22 ខែមិថុនាឆ្នាំ 2022 នៅ www.longbeach.gov/lbplan។

ទីក្រុងឡុងប៊ិច មានគោលបំណងផ្តល់ការសម្របសម្រួលសមហេតុផលសម្រាប់សវនាការសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីប្រជាជនអាមេរិកាំងដែលមានពិការភាព (ADA) ឆ្នាំ 1990។ ប្រសិនបើត្រូវការការសម្របសម្រួលពិសេស សូមទូរសព្ទទៅកាន់លោក Alem Hagos តាមរយៈលេខ (562) 570-7403 យ៉ាងតិចបំផុត 48 ម៉ោងមុនសវនាការសាធារណៈថ្ងៃទី 22 ខែមិថុនាឆ្នាំ 2022។ ប្រជាពលរដ្ឋដែលមានបំណងផ្តល់មតិជាលាយលក្ខណ៍អក្សរ ត្រូវតែផ្តល់មតិនេះត្រឹមថ្ងៃទី 20 ខែមិថុនាឆ្នាំ 2022។ មតិជាលាយលក្ខណ៍អក្សរ ត្រូវតែផ្ញើទៅកាន់ Alem Hagos, Development Services Department, 411 West Ocean Boulevard, Long Beach, California 90802។ អ៊ីមែល៖ alem.hagos@longbeach.gov ។

To request this information in an alternative format or to request a reasonable accommodation, please contact the Development Services Department at longbeach.gov/lbds and 562.570.3807. A minimum of three business days is requested to ensure availability; attempts will be made to accommodate requests with shorter notice.